ស្ថានទូតអូស្ត្រាលី

ប្រចាំនគ្រកម្ពុជា

សេចក្តីប្រកាសពត៌មាន

ការប្រកាស បេក្ខភាពទទួលរង្វាន់ខ្សែភាពយន្តនៅអាស៊ីប៉ាស៊ីហ្វិកក្នុងឆ្នាំ២០០៩

នេះជាលើកទី១ ហើយដែលប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាបេក្ខភាពនៅក្នុងចំណោមអ្នកទទួលរង្វាន់ខ្សែភាពយន្តអាស៊ីប៉ាស៊ីហ្វិក ដោយមានការជ្រើសរើសភាពយន្តឯកសារដ៏មានសក្តានុពលមួយគឺរឿង *L'important, C'est De Rester Vivant (The Main Thing Is To Stay Alive),* សំរាប់ខ្សែភាពយន្តឯកសារដ៏ឆ្នើម ។ ភាពយន្តឯកសារទាំងអស់នោះត្រូវបានផលិតឡើងដោយមានការសហការជាមួយប្រទេសបារាំង ។

អ្នកឈ្នះរង្វាន់ក្នុងវិស័យភាពយន្តឯកសារប្រចាំតំបន់នេះ នឹងត្រូវប្រកាសនៅ ថ្ងៃទី២៦ ខែវិច្ឆិការ ខាងមុខ នៅក្នុងពិធីប្រគល់រង្វាន់ខ្សែភាពយន្តអាស៊ីប៉ាស៊ីហ្វិកប្រចាំឆ្នាំលើកទី៣ នៅ Australia's Gold Coast ។

រង្វាន់ខ្សែភាពយន្តនៅអាស៊ីប៉ាស៊ីហ្វិកនេះ បានប្រកាសរង្វាន់ជាប្រាំបួនប្រភេទសំរាប់បេក្ខភាពទទួលរង្វាន់ទាំងឡាយ ដោយមានខ្សែភាពយន្តចំនួន ៣៧ តំណាងអោយ ១៦ ប្រទេស និងតំបន់ ដូចជា Australia, Cambodia, India, Indonesia, Republic of Iran, Israel, Japan, New Zealand, Palestinian Territories, People's Republic of China, (Mainland China/Hong Kong), Republic of Korea, Russian Federation, Sri Lanka, Thailand and Turkey.

រង្វាន់ខ្សែភាពយន្តនៅអាស៊ីប៉ាស៊ីហ្វិកនេះ គឺជាកិច្ចសហប្រតិបត្តិការរួមមួយរវាង CNN International, UNESCO និង សហព័ន្ធអន្តរជាតិ FIAPF នៃសមាគមន៍ផលិតករភាពយន្ត ។ ភាពយន្តទាំងអស់ត្រូវបានវិនិច្ឆ័យទៅតាមស្នាដៃផលិតសាច់រឿងនៃភាពយន្ត និងវិធីដែលគេបញ្ជាក់អំពីប្រភពដើមនៃវប្ផធម៌របស់ពួកគេ ។

អ្នកឈ្នះរង្វាន់ ត្រូវបានសំរេចដោយគណៈមេប្រយោគអន្តរជាតិដែលដឹកនាំដោយ Huang Jianxin ដែលនឹងជួបប្រជុំឡើងនៅ Australia's Gold Coast មុនពិធីប្រគល់រង្វាន់ថ្ងៃទី ២៦ ខែ វិចិការ ។ បេក្ខភាពទទួលរង្វាន់ក្នុងឆ្នាំ២០០៩ នឹងចូលរួមជាមួយសមាជិកគណៈមេប្រយោគ និងអ្នកឈ្នះរង្វាន់កន្លងមកដែលជាសមាជិកបណ្ឌិតសភាខ្សែភាពយន្ត នៅអាស៊ីប៉ាស៊ីហ្វិក ។

ទំនាក់ទំនងសារពត៌មាន:

Jill Robson
Asia Pacific Screen Awards
M+61 (0) 458404527
jill@apsceenawards.com
www.asiapacificscreenawards.com
www.image.net
22 October 2009